00249749

C26/5/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក ស.ច.ស(អ.ប.ជ) |
| **ឈ្មោះសំណុំរឿង:** | **ខៀវ សំផន** |
| **ដាក់តម្កល់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ |
| **ភាគីអ្នកតម្កល់:** | ក្រុមការពារក្តី |
| **ភាសា:** | ភាសាដើមជាភាសាបារាំង សេចក្តីបកប្រែក្រៅផ្លូវការជាភាសាខ្មែរ |
| **ប្រភេទឯកសារ:** | សាធារណៈ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / DEC / 2008
ម៉ោង (Time/Heure): 08:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Auy

---

## សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន

---

**បញ្ជូនដោយ:**

**មេធាវីរបស់លោក ខៀវ សំផន**

លោក សរ សូវ៉ាន

លោក Jacques VERGÈS

**ជំនួយការ:**

អ្នកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

**បញ្ជូនទៅ:**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00249750



## ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. តាមរយៈដីកាសម្រេចចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានបង្គាប់ឲ្យ "ពន្យារពេលឃុំខ្លួនលោក ខៀវ សំផន បណ្តោះអាសន្ន សម្រាប់រយៈពេលជាអតិបរមាចំនួនមួយឆ្នាំទៀត"[1]។

2. ដោយអនុលោមតាមវិធាន ៧៥នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីបានប្រកាសអំពីគោលបំណងរបស់ខ្លួន ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨[2]។

3. ដោយអនុវត្តន៍តាមមាត្រា ៨.២ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារ និងតាមខ្លឹមសារនៃមាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងវិធាន ៦៣.៧ និង ៧៤.៣ ច) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីសូមដាក់សារណាបណ្តឹងឧទ្ធរណ៍នេះនៅថ្ងៃនេះ។

## II. ការលើកឡើងដោយសង្ខេបអំពីអំណះអំណាង

### ➢ សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ចពន្យារពេលសម្រេចសេចក្តី

4. នៅក្នុងបរិបទនៃនីតិវិធីមួយប្រកបដោយកំហុសទាំងស្រុងនិងដោយភាពយឺតយ៉ាវ និងបរិបទនៃអនិយ័តភាពដែលមិនអាចកាត់ផ្តាច់បានពីបញ្ហានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតលែងអាចសម្រេចសេចក្តីប្រកបដោយយុត្តិធម៌លើការពន្យារពេលការឃុំខ្លួនបានទៀតហើយ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ចពន្យារពេលសម្រេចសេចក្តី។

### ➢ ការពន្យារពេលការឃុំខ្លួនគឺជាសេចក្តីសម្រេចដែលធ្វើឡើងដោយបំពាន

5. ជាគោលការណ៍ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលមួយឆ្នាំ។ ដោយមិនគិតដល់កាលៈទេសៈនានា សហចៅក្រមស៊ើបអង្កេតបែរជាយល់ឃើញថា ខ្លួនត្រូវសម្រេចសេចក្តីលើការបន្តឃុំខ្លួនជាថ្មីជាយថាហេតុណាមួយទៅវិញ ហើយនៅទីបញ្ចប់ ខ្លួនក៏បានសម្រេចពន្យារពេលការឃុំខ្លួន។ សេចក្តីសម្រេចនេះ គឺមិនមានភាពចាំបាច់ហើយក៏ថែមទាំងគ្មានប្រយោជន៍ទៀតផង ហើយតាមការពិតទៅ វាបែរជាធ្វើឲ្យការឃុំខ្លួនមួយដែលធ្វើឡើងដោយបំពានទៅជាស្របច្បាប់ទៅវិញ។

---

[1] ដីកាសម្រេចបន្តថេរវេលាការឃុំខ្លួនបណ្តោះអាសន្ន (តទៅនេះហៅថា "ដីកាសម្រេចបន្តឃុំខ្លួន") ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/4*

[2] សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍ ថ្ងៃទី២៦ វិច្ឆិកា ២០០៨ *ឯកសារតុលាការ C26/5*

➢ **លោក ខៀវ សំផន ត្រូវបានឃុំខ្លួនដោយអនុលោមតាមលិខិតមួយដែលមោឃៈ ហើយដោយហេតុដូច្នេះ គេត្រូវតែ ដោះលែងគាត់ឲ្យមានសេរីភាពជាបន្ទាន់**

6. ដីកាសម្រេចពន្យារពេលការឃុំខ្លួនសម្អាងលើលិខិតមួយដែលមោឃៈ ហើយនេះគឺជាលិខិតមួយដែលគ្មានអត្ថិភាព។ ដូច្នេះ លោក ខៀវ សំផន ត្រូវបានគេឃុំខ្លួនដោយគ្មានកិច្ចគតិយុត្ត។ គេត្រូវតែដោះលែងគាត់ឲ្យមានសេរីភាព ហើយគាត់មានសិទ្ធិទទួលបានសំណងសម្រាប់ពេលវេលាដែលគាត់បានស្ថិតនៅក្នុងការឃុំខ្លួនដោយអយុត្តិធម៌។

## III. **អង្គហេតុ និង នីតិវិធី**

### **ក. អង្គហេតុ**

7. អស់រយៈពេលចំនួនមួយឆ្នាំ និង១៧ថ្ងៃមកហើយដែលលោក ខៀវ សំផន ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ «បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើមនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត) និងឧក្រិដ្ឋកម្មសង្គ្រាមដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ (អំពើមនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយនិងសុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬជន្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់) »[3]។

8. អស់រយៈពេលចំនួនមួយឆ្នាំនិង១៧ថ្ងៃមកហើយដែលលោក ខៀវ សំផន ត្រូវបានឃុំខ្លួនដោយសារ « តាមរយៈឯកសារ និងចម្លើយសាក្សីជាច្រើនដែលមានក្នុងសំណុំរឿង» សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា មានហេតុផលនានាដែលអាចឲ្យជឿជាក់ថា លោក ខៀវ សំផន បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន។[4]

9. ផ្ទុយមកវិញ អស់រយៈពេលចំនួនមួយឆ្នាំនិង១៧ថ្ងៃមកហើយ លោក ខៀវ សំផន ពុំអាចការពារខ្លួនឯងបានទេ។ លោក VERGÈS សហមេធាវីអន្តរជាតិដែលត្រូវបានជ្រើសតាំងមកការពារក្តីឲ្យគាត់ ពុំអាចពិនិត្យមើលសំណុំរឿងស៊ើបអង្កេតជាភាសាដែលគាត់អាចយល់បានឡើយ។ ដូច្នេះ

[3] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26*

[4] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26* កថាខណ្ឌ ៥

ក្រុមការពារក្តីរបស់លោក ខៀវ សំផន ត្រូវបានកាត់ផ្តាច់ និងថែមទាំងមិនអាចចូលរួមក្នុងនីតិវិធីស្របតាមលក្ខខណ្ឌសម្រាប់ការកាត់ក្តីដោយត្រឹមត្រូវបានឡើយ។

10. ទោះជាមានស្ថានភាពនៃអង្គហេតុនេះក៏ដោយ និងតាមរយៈដីកាសម្រេចចំនួនពីរបន្តបន្ទាប់គ្នា សហចៅក្រមស៊ើបអង្កេតបានសម្រេចនៅពេលថ្មីៗនេះថា ការឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន មិនត្រឹមតែត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែការឃុំខ្លួននេះត្រូវតែពន្យារពេលសម្រាប់រយៈពេលបន្ថែមចំនួនមួយឆ្នាំថែមទៀតផង។

11. ដោយបង្គាប់ឲ្យមានការពន្យារពេលការឃុំខ្លួននេះ សហចៅក្រមស៊ើបអង្កេតបានប្រែក្លាយការដោះលែងឲ្យមានសេរីវិញឲ្យទៅជាបំណងប្រាថ្នាដ៏គួរឲ្យគោរពតែមិនអាចទៅរួច ហើយបានធ្វើឲ្យការឃុំខ្លួនក្លាយជាគោលការណ៍មួយទៅវិញ។ ស្ថានភាពបែបនេះមិនត្រឹមតែគួរឲ្យទើសទាល់ចិត្តប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងនិងជាពិសេសខុសច្បាប់ទៀតផង។

## ខ. នីតិវិធី

12. អស់រយៈពេលជិតមួយឆ្នាំមកហើយដែលសហមេធាវីការពារក្តីប៉ុនប៉ងធ្វើឲ្យមានសុពលភាព នូវសិទ្ធិដាច់ខាត និងដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់លោក ខៀវ សំផន ចំពោះការការពារខ្លួនដ៏ពិតប្រាកដមួយ។

13. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ លោក VERGÈS បានស្នើជាបឋមទៅសហចៅក្រមស៊ើបអង្កេតឲ្យបង្គាប់ឲ្យធ្វើការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ដោយគូសបញ្ជាក់ថា គាត់មិនអាចការពារកូនក្តីរបស់គាត់បានទេ បើមិនអាចពិនិត្យឯកសារសំណុំរឿងព្រហ្មទណ្ឌបានដោយពិតប្រាកដទេនោះ[5]។

14. បន្ទាប់មកទៀត នៅថ្ងៃទី២៣ មេសា ២០០៨ ក្រុមការពារក្តីបានលើកឡើងអំពីការរំលោភបំពាននេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយអង្គបុរេជំនុំជម្រះបានសម្រេចលើកពេលសវនាការទៅកាលបរិច្ឆេទមួយដែលត្រូវកំណត់នៅពេលក្រោយ។

15. នៅទីបញ្ចប់ គឺនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ បន្ទាប់ពីការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបង្គាប់ឲ្យមានការបកប្រែឯកសារសំណុំរឿង[6] ក្រុមការពារក្តីបានស្នើទៅអង្គបុរេជំនុំ

---

[5] រឿងក្តី ខៀវ សំផន "កំណត់ហេតុសាកសួរចម្លើយ" *ឯកសារតុលាការ D75*

[6] សម្ងាត់ កំណត់ហេតុសវនាការថ្ងៃទី២៣ ខែមេសា ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/25*

ជម្រះឲ្យកត់សម្គាល់អំពីការរំលោភសិទ្ធិរបស់ក្រុមការពារក្តី ដែលបណ្តាលមកពីសេចក្តីសម្រេចខាងលើនេះ និងមកពីអវត្តមាននៃការបកប្រែ ហើយឲ្យបង្គាប់ឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាព ដោយសារតែកំហុសផ្នែកនីតិវិធី[7]។

16. នៅថ្ងៃទី២១ សីហា ២០០៨ តាមការបង្គាប់របស់អង្គបុរេជំនុំជម្រះ ក្រុមមេធាវីការពារក្តីបានបញ្ជាក់ឡើងវិញជាថ្មីអំពីគោលជំហររបស់ខ្លួនលើបញ្ហានេះ[8]។ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះបែរជាយល់ឃើញថា គោលជំហរនេះមិនជំទាស់ទៅនឹងការសម្រេចសេចក្តីលើនីត្យានុកូលភាពនៃការឃុំខ្លួនឡើយ[9]។

17. ដោយហេតុដូច្នេះ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ ក្រុមការពារក្តីត្រូវបង្ខំចិត្តដកបណ្តឹងឧទ្ធរណ៍នេះ[10] ហើយនៅក្នុងពេលជាមួយគ្នានោះ បានស្នើទៅសហចៅក្រមស៊ើបអង្កេតឲ្យបង្គាប់ឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាព[11]។ សំណើនេះត្រូវបានបដិសេធដោយសេចក្តីសម្រេចចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[12]។

18. ម្យ៉ាងទៀត នៅថ្ងៃទី៣១ តុលា ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងមកសហមេធាវីការពារក្តីអំពីគោលបំណងរបស់ខ្លួនក្នុងការបន្តការឃុំខ្លួនបណ្តោះអាសន្ន សម្រាប់រយៈពេលមួយឆ្នាំទៀត[13]។

19. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយរំឭកឡើងវិញអំពីលក្ខណៈនៃការធ្វើឡើងស្រេចតែអំពើចិត្តចំពោះការឃុំខ្លួនបណ្តោះអាសន្ន និងលក្ខណៈអយុត្តិធម៌នៃនីតិវិធី ក្រុមការពារក្តីបានលើកហេតុផលអំពីអសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបង្គាប់ឲ្យមានការពន្យារពេលការឃុំខ្លួននេះ ហើយបានស្នើដល់សហចៅក្រមស៊ើបអង្កេតឲ្យ "ពន្យារពេលក្នុងការចេញសេចក្តីសម្រេចលើការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន រហូតដល់មានសេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍របស់

---

[7] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/1*

[8] សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/28*

[9] សេចក្តីបង្គាប់ស្តីពីការបន្តនីតិវិធី ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១២ តុលា ២០០៨ *ឯកសារតុលាការ C26/I/29*

[10] សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/30*

[11] សំណើសុំជាបន្ទាន់ឲ្យដោះលែងឲ្យមានសេរីភាព ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40*

[12] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40/4*

[13] សេចក្តីជូនដំណឹង (វិធាន ៦៣.៧) *ឯកសារតុលាការ C26/2*

អង្គបុរេជំនុំជម្រះ ប្រឆាំងនឹងការបដិសេធការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌ។ (...) នៅក្នុងចន្លោះពេលនេះ ក្រុមការពារក្ដីបានស្នើទៅសហចៅក្រមស៊ើបអង្កេត "ឲ្យបង្គាប់ឲ្យដោះលែងលោក ខៀវ សំផន ជាបណ្ដោះអាសន្នដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកតុលាការទៅតាមលក្ខខណ្ឌដែល(ខ្លួន) យល់ឃើញថាមានលក្ខណៈសមស្រប"[14]។

20. បន្ទាប់ពីបានដឹងអំពីការជំទាស់របស់ក្រុមការពារក្ដី សហចៅក្រមស៊ើបអង្កេតបែរជាបង្គាប់ឲ្យពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នលោក ខៀវ សំផន សម្រាប់រយៈពេលអតិបរមាចំនួនមួយឆ្នាំដោយវាយតម្លៃខ្លួនឯងថា ពិតជាមានតួនាទីនិងពិតជាអាចបង្គាប់ឲ្យពន្យារពេលការឃុំខ្លួនបានសម្រាប់រយៈពេលមួយឆ្នាំបន្ថែមទៀត[15]។

21. នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្ដីបានប្រកាសអំពីគោលបំណងរបស់ខ្លួន ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចខាងលើ[16]។ នៅថ្ងៃនេះ សហមេធាវីការពារក្ដីដាក់សារណាបណ្ដឹងឧទ្ធរណ៍នេះ។

## IV. **បទប្បញ្ញត្តិច្បាប់សំខាន់ៗ**

### ក) លក្ខខណ្ឌនៃនីត្យានុកូលភាពនៃការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្ន

22. វិធាន ៦៣.៦ ក) នៃវិធានផ្ទៃក្នុងចែងថា "ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន (...) មិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នបន្ថែមម្ដងបាន ១ (មួយ) ឆ្នាំ"[17]។

23. វិធាន ៦៣. (៧) បញ្ជាក់ថា "ទោះជាយ៉ាងណាក៏ដោយ ការពន្យាពេលមិនត្រូវឲ្យលើសពី ២ (ពីរ) ដងបានឡើយ[18]" ហើយ "ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើបានតែក្នុងករណី

---

[14] ការជំទាស់របស់ក្រុមការពារក្ដី ទាក់ទងនឹងការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្ន (តទៅនេះ ហៅថា "ការជំទាស់របស់ក្រុមការពារក្ដី") ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/3*

[15] ដីកាសម្រេចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្ន (តទៅនេះ ហៅថា "ដីកាសម្រេចពន្យារពេល") ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/4*

[16] សេចក្ដីជូនដំណឹងបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី២៦ វិច្ឆិកា ២០០៨ *ឯកសារតុលាការ C26/5*

[17] សូមអាន មាត្រា ២១០ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[18] សូមអាន មាត្រា ២១០ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្ដល់រយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីទុកពេលឲ្យប្ដឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត (...)"។ មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបញ្ជាក់បន្ថែមថា "កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្ដីរបស់ខ្លួន"។

24. ដីកាសម្រេចពន្យារពេលត្រូវ "មានសម្អាងហេតុត្រឹមត្រូវ"[19] "ធ្វើជាលាយលក្ខណ៍អក្សរ"[20] និង "ច្បាស់លាស់"[21] ហើយដីកាសម្រេចនេះ "បើកផ្លូវប្ដឹងឧទ្ធរណ៍"[22]។

## ខ) វិធីឧបាស្រ័យទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន

25. ដោយអនុលោមតាមវិធាន ៧៤.៣ ច) នៃវិធានផ្ទៃក្នុង "ដីកាសម្រេចពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន (...) បើកផ្លូវប្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ"[23]។

26. មាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្ន សាលដីការបស់សភាស៊ើបសួរ ត្រូវសម្រេចចេញនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឲ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះ បង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ"។

27. លើសពីនេះទៅទៀត មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា "នៅរាល់ពេលដែលបានទទួលបណ្ដឹង សភាស៊ើបសួរពិនិត្យមើលពីនីយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តិទៅដ៏ល្អនៃនីតិវិធីនេះ។ កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាច

---

[19] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និង វិធាន ៦៣ (៧) នៃវិធានផ្ទៃក្នុង

[20] វិធាន ៦៣ (៧) នៃវិធានផ្ទៃក្នុង

[21] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[22] វិធាន ៦៣ (៧) នៃវិធានផ្ទៃក្នុង

[23] សូមអានមាត្រា ២៦៧ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ចាត់ទុកជាមោឃៈ ដោយឯកឯង នូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូច ដែលមានចែងនៅក្នុងមាត្រា ២៨០[24] (អានុភាពនៃមោឃកម្ម) នៃក្រមនេះ”[25]។

28. នៅទីបញ្ចប់ មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា “សាលដីកា នៃសភាស៊ើបសួរ (...) នៃសាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន”។

## គ) សិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទនៅក្នុងរឿងក្តីនេះ

29. បទប្បញ្ញត្តិដែលទាក់ទងនឹងសិទ្ធិជាមូលដ្ឋាននៅក្នុងរឿងក្តីនេះ និងដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានបង្ហាញឲ្យឃើញជាលើកទីមួយ ដើម្បីគាំទ្រសារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨[26] ហើយជាលើកទីពីរ គឺដើម្បីគាំទ្រដល់ការជំទាស់របស់ក្រុមការពារក្តីទាក់ទងនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ (តទៅនេះ ហៅថា “ការជំទាស់របស់ក្រុមការពារក្តី”)[27]។ ដោយហេតុដូច្នេះ ប្រសិនជាត្រូវធ្វើ ក្រុមការពារក្តីសូមស្នើទៅសហចៅក្រមស៊ើបអង្កេត ឲ្យយោងទៅកថាខណ្ឌសមស្របនៃឯកសារទាំងពីរនេះ។

30. ក្រុមការពារក្តីក៏សូមរំឭកផងដែរថា ដោយអនុលោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(PIDCP)-ជាសន្ធិសញ្ញាដែលអាចអនុវត្តន៍បានដោយផ្ទាល់នៅចំពោះមុខអ.វ.ត.ក-នៅមាត្រា ៩(៤) ចែងថា “ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែ

---

[24] “កាលណាបានទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្តឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ។ កិច្ច ឬលិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។”

[25] ដោយមាត្រានេះមិនសមមូលជាមួយនឹងវិធានផ្ទៃក្នុង សហមេធាវីការពារក្តីយល់ឃើញថា មាត្រានេះត្រូវតែយកមកអនុវត្តន៍ជាចាំបាច់ (សូមអាន និងដោយរក្សាសិទ្ធិគ្រប់យ៉ាង សេចក្តីសម្រេចទាក់ទងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចដែលបដិសេធបណ្តឹងសុំមោឃៈភាព *ឯកសារតុលាការ D55/I/8* ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ១៥)

[26] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/1* ពីកថាខណ្ឌ ១៦ ដល់ ២៧

[27] ការកត់សម្គាល់របស់ក្រុមការពារក្តី កថាខណ្ឌ ១៧ និង ១៨

មានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឲ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់”[28]។

31. ដោយអនុលោមតាមមាត្រា (៩.៥) “ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង។”

## V. អំណះអំណាង

### ក) សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ចពន្យារពេលសម្រេចសេចក្តី

32. នៅក្នុងស្ថានភាពនៃនីតិវិធីនេះ និងនៅពេលដែលខ្លួនបានប្រកាសអំពីគោលបំណងរបស់ខ្លួនក្នុងការបន្តការឃុំខ្លួនជាថ្មីនោះ[29] សហចៅក្រមស៊ើបអង្កេតមិនមានជម្រើសអ្វីផ្សេងទៀតក្រៅពីពន្យារពេលសម្រេចសេចក្តីនោះទេ។

### ១) នីតិវិធីដ៏យឺតយ៉ាវ និងមានកំហុសទាំងស្រុង

33. ក្រុមការពារក្តីសូមនិយាយរឿងនេះម្តងទៀត គឺការឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន ធ្វើឡើងតាមតែអំពើចិត្ត។ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបង្គាប់ឲ្យធ្វើការបកប្រែទាំងស្រុងនូវឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន មិនមានសម្អាងលើមូលដ្ឋានច្បាប់ណាមួយទេ ហើយឆ្លើយតបតែទៅនឹងភាពចាំបាច់ដែលមានលក្ខណៈសេដ្ឋកិច្ចសុទ្ធសាធ។ លើសពីនេះទៅទៀត អវត្តមាននៃការបកប្រែនិងវិធានការណ៍ដែលត្រូវបង្គាប់ ដើម្បីបំពេញចន្លោះអវត្តមាននេះ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសិទ្ធិរបស់លោក ខៀវ សំផន ហើយការរំលោភសិទ្ធិទាំងនេះនៅតែបន្ត។ ដូច្នេះ គ្រប់កិច្ចនីតិវិធីដែលធ្វើឡើងប្រឆាំងនឹងលោក ខៀវ សំផន គឺមានកំហុសទាំងស្រុង ដោយចាប់ផ្តើមពីដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅ[30]។

---

[28] បទប្បញ្ញត្តិនេះក៏មានចែងផងដែរនៅមាត្រា ៥(៤) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបដែល ថ្វីបើមិនអាចយកមកអនុវត្តន៍បានដោយផ្ទាល់ក៏ដោយ ក៏អាចប្រើជាមគ្គុទ្ទេសក៏នៅក្នុងសេចក្តីសម្រេចនេះបានដែរ៖ “ជនណាដែលត្រូវបានគេដកហូតសេរីភាព (...) មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឲ្យតុលាការអាចសម្រេចនៅក្នុងរយៈពេលឆាប់រហ័ស ទាក់ទងនឹងនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំបើការឃុំខ្លួននោះមិនស្របច្បាប់”

[29] សេចក្តីជូនដំណឹងប្តឹងឧទ្ធរណ៍ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ D26/5*

[30] ក្រុមការពារក្តីនឹងលែងបញ្ជាក់លម្អិតហើយ ការរំលោភនិងផលវិបាកទាំងអស់ដែលបណ្តាលមកពីរឿងនេះ ទាក់ទងនឹងនីត្យានុកូលភាពនៃនីតិវិធី។ នៅត្រង់ចំណុចទាំងនេះ ក្រុមការពារក្តីសូមយោងទៅអំណះអំណាងដែលលើកឡើងដើម្បីគាំទ្រដល់

00249758



34. ដើម្បីបដិសេធពិនិត្យពិចារណាលើស្ថានភាពនៃអង្គហេតុនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា "បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយជនត្រូវចោទ (ស្តីពីបញ្ហានៃការបកប្រែ) មិនមានអានុភាពបង្អង់ការអនុវត្ត" ហើយថា (ដោយហេតុដូច្នេះ) ភាគីនានាបានដឹងយ៉ាងច្បាស់អំពីសិទ្ធិដែលត្រូវអនុវត្តនៅដំណាក់កាលនៃនីតិវិធីនេះ[31]"។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានចង្អុលបង្ហាញថា "បើសិនជាត្រូវធ្វើ ខ្លួននឹងត្រូវទាញយកផលវិបាកទាំងអស់នៃសេចក្តីសម្រេចប្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ។"

35. ជាលក្ខណៈឡូស៊ិក អំណះអំណាងនេះមិនមែនមិនបំភ័ន្តនោះទេ។ ការកត់សម្គាល់អំពីកង្វះខាតទាក់ទងនឹងការបកប្រែត្រូវបានលើកឡើងជាលើកទីមួយ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ នៅពេលសាកសួរចម្លើយលោក ខៀវ សំផន ដោយសហចៅក្រមស៊ើបអង្កេត។ នៅកាលបរិច្ឆេទនោះ សហមេធាវីអន្តរជាតិ លោក VERGÈS បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ស្តីពីភាពបន្ទាន់នៃស្ថានភាព។ ជាការពិតណាស់ នៅក្នុងរយៈពេលនៃការសាកសួរចម្លើយនោះ លោក VERGÈS បានគូសបញ្ជាក់យ៉ាងច្បាស់ថា "ឯកសារចំនួន ១៦ ០០០ ទំព័រ ដែលជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតមកដល់ពេលនេះ មិនត្រូវបានគេបកប្រែជាភាសាបារាំងទេ ហើយភាសាបារាំងនេះជាភាសាផ្លូវការមួយក្នុងចំណោមភាសាជាផ្លូវការរបស់តុលាការ (...) [ហើយថា] ដរាបណាការបកប្រែទាំងនេះមិនត្រូវបានធ្វើទេ [ក្រុមការពារក្តី] [នឹង]នៅតែបន្តការបដិសេធ[របស់ខ្លួន]ក្នុងការឆ្លើយតបទៅនឹងសំណួរផ្សេងៗ"[32]។

36. បន្ទាប់ពីនៅស្ងៀមស្ងាត់អស់រយៈពេលចំនួនពីរខែមក លោក VERGÈS បានលើកឡើងអំពីអនិយ័តភាពនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ។[33]

37. រយៈពេលចំនួនពីរខែបន្ទាប់មក ក្រុមការពារក្តីរបស់លោក ខៀវ សំផន បានទាក់ទងទៅផ្នែកគ្រប់គ្រងតុលាការ ដើម្បីសួរថាតើឯកសារសំណុំរឿងត្រូវបានគេបកប្រែជិតចប់ហើយឬនៅ[34]។ ក្រុមការពារមិនបានទទួលចម្លើយមួយណាឡើយ។

---

បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌ។ ("សារណារបស់ក្រុមការពារក្តីស្តីពីការបកប្រែ" កថាខណ្ឌ ២៨ ដល់ ៥៤, ៥៥ ដល់ ៧១ និង ៧២ ដល់ ៧៨)

[31] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ១៥

[32] កំណត់ហេតុសាកសួរចម្លើយ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ *ឯកសារតុលាការ 2008 D75*

[33] សេចក្តីសម្រេចលើកពេលសវនាការស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/25*

38. នៅទីបញ្ចប់ គឺនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ប៉ុណ្ណោះ - គឺរយៈពេលចំនួនបួនខែគត់បន្ទាប់ពីសំណើដែលបានធ្វើឡើងដោយលោក VERGÈS ទៅសហចៅក្រមស៊ើបអង្កេត - ដែលចម្លើយមួយត្រូវបានផ្តល់ឲ្យមកក្រុមការពារក្តី៖ ភាសាបារាំងពិតជាភាសាផ្លូវការមួយមែន ប៉ុន្តែការបកប្រែឯកសារសំណុំរឿងទាំងស្រុងមិនអាចធ្វើបានទេ ប្រសិនបើគេមានបំណងជំនុំជម្រះក្តីលោក ខៀវ សំផន នៅក្នុងរយៈពេលមួយសមស្រប។ ដូច្នេះ សូមក្រុមការពារក្តីកុំស្នើឲ្យបកប្រែឯកសារសំណុំរឿងទាំងមូល ហើយត្រូវចាត់ចែងដើម្បីទទួលបានការបកប្រែឯកសារភស្តុតាងដែលខ្លួនយល់ឃើញថាមានភាពសមហេតុផលបំផុត[35]។ ក្រុមការពារក៏បានប្តឹងឧទ្ធរណ៍ភ្លាមៗប្រឆាំងនឹងសំណើនេះ[36]។

39. សវនាការស្តីពីបញ្ហានេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ហើយសេចក្តីសម្រេចទំនងជានឹងមិនធ្វើឡើងនៅមុនឆ្នាំ ២០០៩ ឡើយ គឺមានរយៈពេលចំនួនមួយឆ្នាំ បន្ទាប់ពីអន្តរាគមន៍លើកទីមួយរបស់លោក ខៀវ សំផន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ នេះគឺជានីតិវិធីដ៏វែងបំផុតមួយដែលរយៈពេលនៃនីតិវិធីនេះ បានបង្កព្យសនកម្មហួសហេតុចំពោះជនត្រូវចោទ។ ដោយហេតុដូច្នេះ ក្រុមការពារក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនអាចគេចខ្លួននៅពីក្រោយការបង្អង់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបកប្រែបានទេ។

40. ថ្វីបើខ្លួនមិនចាត់ទុកថាមានការពាក់ព័ន្ធទៅនឹងនីតិវិធីដែលកំពុងប្រព្រឹត្តទៅ នៅចំពោះមុខអង្គបុរេជំនុំជម្រះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតចង្អុលបង្ហាញដែរថា ខ្លួន"នឹងទាញយក ប្រសិនជាត្រូវធ្វើ នូវគ្រប់ផលវិបាកទាំងអស់នៃសេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ"។

41. នៅក្នុងអត្ថន័យនៃអានុភាពប្រកបដោយសារប្រយោជន៍ ការទាញរកហេតុផលនេះមិនមានភាពឡូស៊ិចទេ។ ជាការពិតណាស់ នៅក្នុងករណីដែលអង្គបុរេជំនុំជម្រះសម្រេចចាត់ទុកនីតិវិធីជាមោឃៈ ហើយសម្រេចថាការឃុំខ្លួនគឺធ្វើឡើងតាមតែអំពើចិត្តនោះ សហចៅក្រមស៊ើបអង្កេតពិតជាមិនអាចផ្តល់នូវអានុភាពមានសារប្រយោជន៍ពិតប្រាកដចំពោះសេចក្តីសម្រេចនេះបានទេ។ នៅត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ភាពយឺតយ៉ាវក្នុងការចេញសាលក្រមអាច

---

[34] សេចក្តីចម្លងនៃលិខិតផ្ញើរទៅលោក តូនី ក្រាញ់ ស្តីពីបញ្ហានៃការបកប្រែ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ ហើយបានផ្ញើរទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A185*

[35] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗទាក់ទងនឹងការបកប្រែ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A190*

[36] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/1*

ធ្វើឲ្យបុគ្គលម្នាក់បាត់បង់សិទ្ធិរបស់ខ្លួន ក្នុងការទទួលបានការការពារដោយច្បាប់" នៅក្នុងករណីដែល "ភាគីនានាលែង [អាច] ទទួលបានលទ្ធផលដែលខ្លួនប៉ងប្រាថ្នាចង់បានហើយនោះ"[37]។

42. ដូច្នេះ នៅក្នុងរឿងក្ដីនេះ ផលប្រយោជន៍ដែលលោក ខៀវ សំផន អាចប្រាថ្នាចង់បាន - ជាអាទិ៍ការបញ្ឈប់*ជាបន្ទាន់* នូវការរំលោភសិទ្ធិរបស់គាត់ ក្នុងការទទួលបានសេរីភាពនិងសច្ចធារណ៍និរទោស - គឺត្រូវបានគេបដិសេធចោលជាស្ថាពរ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអាចសម្រេចធ្វើឲ្យអានុភាពនៃភាពយឺតយ៉ាវនេះទៅជាតូចបំផុត ដោយបដិសេធមិនពន្យារពេលការឃុំខ្លួន។ ប៉ុន្តែរឿងនេះមិនត្រូវបានគេអនុវត្តន៍ទេ។

## ២) ការប្រកាន់ចិត្តជាប់ជាមុនដោយពិតប្រាកដប្រឆាំងនឹងគោលជំហររបស់ក្រុមការពារក្ដី

43. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតធ្វើការរំឭកថា "សមត្ថកិច្ចក្នុងការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ការរក្សាទុកនិងការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានផ្ដល់ឲ្យដល់សហចៅក្រមស៊ើបអង្កេត នៅចំពោះមុខអ.វ.ត.ក [ហើយថានេះគឺជា] ដំណោះស្រាយដែលបានអនុម័ត ដោយអនុលោមនិងដោយដូចគ្នាជាមួយនឹងប្រព័ន្ធច្បាប់កម្ពុជាដែលកំពុងស្ថិតនៅជាធរមាន"[38] ព្រមទាំងដោយត្រូវគ្នាជាមួយនឹង "គោលការណ៍ដែលមាននៅក្នុងច្បាប់អន្តរជាតិ"។

44. ជាបឋម ក្រុមការពារសូមធ្វើការរំឭកថា អ.វ.ត.ក ស្ថិតនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ហើយជាការពិតណាស់ដែលនៅក្នុងច្បាប់កម្ពុជា ចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចបង្គាប់ឲ្យធ្វើការឃុំខ្លួនបណ្ដោះអាសន្ន ព្រមទាំងពន្យារពេលការឃុំខ្លួននេះ។ ផ្ទុយទៅនឹងអ្វីដែលសហចៅក្រមស៊ើបអង្កេតអះអាង[39] សមត្ថកិច្ចជាគោលការណ៍នេះមិនត្រូវបានសហមេធាវីការពារក្ដីលើកយកមកនិយាយនោះទេ។

45. សហមេធាវីការពារក្ដីគ្រាន់តែធ្វើការរំឭកថា ក្នុងឋានៈខ្លួនជាអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតស្ថិតនៅក្នុង "ភាពឡូស៊ិចនៃការជាប់ពាក់ព័ន្ធ" នៅក្នុងការស្វែងរកភស្ដុតាង។ តួនាទីនេះមិនច្បាស់ជានាំមកនូវភាពលម្អៀងសម្រាប់ខ្លួននោះទេ ប៉ុន្តែតួនាទីនេះធ្វើឲ្យសហចៅក្រមស៊ើបអង្កេតស្ថិតនៅក្នុងស្ថានភាពមួយដែលពិបាកនឹងគ្រប់គ្រងបំផុត ហើយដោយហេតុដូច្នេះ វាតម្រូវឲ្យសហ

---

[37] សេចក្ដីសម្រេចស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងនឹងការតែងតាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដោយលើកឡើងពី *Boodhoo និងអ្នកដទៃទៀត* អគ្គស្នងក្ដីរបស់ *Trinidad និង Tobago*, [2004], UKPC17 កថាខណ្ឌ ១២

[38] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ២០

[39] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ១៧ ដល់ ២២

ចៅក្រមស៊ើបអង្កេតមានភាពម៉ឺងម៉ាត់ដ៏ខ្ពស់បំផុត និងមានការប្រុងប្រយ័ត្នខ្លាំងបំផុតនៅក្នុងផ្នែកនេះ[40]។

46. នៅក្នុងរឿងក្តីមួយដែលលើកយកមកនិយាយដោយសហចៅក្រមស៊ើបអង្កេត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីយល់ឃើញថា គេ "មិនអាចបដិសេធទាំងស្រុងបានទេនូវលទ្ធភាពដែលថា សេចក្តីសម្រេចដែលចេញដោយចៅក្រម ឬដោយអង្គជំនុំជម្រះមួយ មានភាពគ្រប់គ្រាន់ដោយខ្លួនឯង ដើម្បីបង្កើតឲ្យមានការប្រកាន់ចិត្តជាប់ជាមុនដ៏ពិតប្រាកដមួយ [ប៉ុន្តែថា] រឿងនេះអាចកើតមានបានតែក្នុងកាលៈទេសៈដ៏ពិសេសៗប៉ុណ្ណោះ"[41]។

47. នៅក្នុងរឿងក្តីនេះ គឺមានកាលៈទេសៈបែបនេះ ហើយត្រូវតែកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតមិនអាចចេញសេចក្តីសម្រេចមួយដែលមានភាពលម្អៀងទេ ដោយបានឃើញគោលជំហររបស់សហចៅក្រមស៊ើបអង្កេតស្តីពីបញ្ហានៃការបកប្រែ និងកាលៈទេសៈដ៏ពិសេសនៃនីតិវិធី។

48. ជាបឋមនិងដោយផ្ទុយទៅនឹងអ្វីដែលសហចៅក្រមស៊ើបអង្កេតអះអាង នីត្យានុកូលភាពនៃការពន្យារពេលការឃុំខ្លួនគឺ "អាស្រ័យទាំងស្រុងទៅនឹងដំណោះស្រាយនៃបណ្តឹងឧទ្ធរណ៍ដែលកំពុងប្រព្រឹត្តទៅ ប្រឆាំងនឹងដីកាស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនីមួយៗទាក់ទងនឹងការបកប្រែ"[42]។

49. ជាការពិតណាស់ ការពន្យារពេលការឃុំខ្លួនអាចបង្គាប់ឲ្យធ្វើបានតែបន្ទាប់ពីបានជូនដំណឹងទៅជនត្រូវចោទនិងមេធាវីរបស់ជនត្រូវចោទ ហើយនៅពេលដែលជនត្រូវចោទមានមេធាវីការពារ មេធាវីនេះត្រូវបង្ហាញអំពីមធ្យោបាយការពារក្តីរបស់ខ្លួន[43]។ នៅក្នុងរឿងក្តីនេះ បើគ្មានការបកប្រែទេ ក្រុមការពារក្តីមិនអាចបង្ហាញអំពីមធ្យោបាយការពារក្តីរបស់ខ្លួន ទាក់ទងនឹងហេតុផលដែលអាចជឿជាក់បានទេ។ ផ្ទុយមកវិញ នេះគឺជាលក្ខខណ្ឌ *មិនអាចខ្វះបាន*តែមួយគត់ដើម្បីប្រកាសអំពីការឃុំខ្លួន ហើយនេះក៏ជាលក្ខខណ្ឌដ៏សំខាន់ផងដែរក្នុងការអនុម័តដីកាសម្រេចពន្យារពេល[44]។

50. លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតមិនអាចពិនិត្យពិចារណាលើទស្សនៈរបស់ក្រុមការពារក្តីលើចំណុចនេះបានទេ៖ តាមការពិត សហចៅក្រមស៊ើបអង្កេតទទួលបន្ទុកធ្វើការស៊ើប

[40] ការជំទាស់របស់ក្រុមការពារក្តី កថាខណ្ឌ ២៩ ដល់ ៣២

[41] TPIY- *រដ្ឋអាជ្ញា c. Blagojevic*, IT-02-60, សេចក្តីសម្រេចទាក់ទងនឹងសំណើដែលស្នើឡើងដោយ Blagojevic ដោយអនុវត្តតាមមាត្រា 15 B) នៃវិធាន ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ១៤ ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត

[42] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ១៦

[43] វិធាន ៦៣.៧ និង មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[44] ដូចដែលក្រុមការពារក្តីបានលើកឡើងរួចមកហើយនៅក្នុងការជំទាស់របស់ខ្លួន នៅក្នុងច្បាប់បារាំង ការជជែកដេញដោលនៅមុនការបន្តការឃុំខ្លួនជាថ្មី គឺជាលក្ខខណ្ឌដ៏សំខាន់សម្រាប់ការសម្រេចពន្យារពេល។

អង្កេត ហើយក្រុមការពារក្តីបានលើកឡើងអំពីកង្វះការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងបញ្ហានៃការបកប្រែ។ ហើយលើសពីនេះទៅទៀតនោះ សហចៅក្រមស៊ើបអង្កេតបានចូលរួមចំណែកក្នុងភាពយឺតយ៉ាវនៅក្នុងនីតិវិធី។ ហើយនៅទីបញ្ចប់ សហចៅក្រមចាត់ទុកថា បញ្ហានៃការបកប្រែមិនរំលោភដល់សិទ្ធិរបស់ក្រុមការពារក្តីទេ។

51. វាគឺជាការសមហេតុសមផលដែលសហចៅក្រមស៊ើបអង្កេតបដិសេធមិនប្រែប្រួលសំដី ទាក់ទងនឹងបញ្ហានេះ។ សហចៅក្រមក៏អាចបដិសេធមិនទទួលស្គាល់តួនាទីរបស់ខ្លួន នៅក្នុងនីតិវិធីទាក់ទងនឹងការបកប្រែផងដែរ។ ប៉ុន្តែ នេះគឺពិតជាសាទុក្ខដែលក្រុមការពារក្តីប្តឹងចំពោះខ្លួន។

52. ដោយហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនត្រឹមតែមិនទោរទន់ក្នុងការព្រមទទួលយកទស្សនៈរបស់ក្រុមការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែខ្លួនថែមទាំងមិនអាចសម្រេចសេចក្តីជាគុណប្រយោជន៍ដល់ខ្លួនទៀតផង ទាក់ទងនឹងចំណុចទាំងនេះ។ ដូច្នេះ ក្រុមការពារក្តីយល់ឃើញថា "អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណនិងដែលបានទទួលព័ត៌មានគ្រប់គ្រាន់ម្នាក់ នឹងគាំទ្រចំពោះសេចក្តីសន្និដ្ឋានរបស់ក្រុមការពារក្តីដែលថា អាកប្បកិរិយា [របស់សហចៅក្រមស៊ើបអង្កេត] គឺបណ្តាលមកពីការប្រកាន់ចិត្តជាប់ជាមុនប្រឆាំងនឹងគោលជំហររបស់អ្នកប្តឹងតវ៉ា[45]" ទោះជាអំណះអំណាងដែលលើកឡើងដោយក្រុមការពារក្តីមានលក្ខណៈបែបណាក៏ដោយ។

## ក) សេចក្តីសម្រេចបន្តឃុំខ្លួនជាសេចក្តីសម្រេចធ្វើឡើងដោយបំពាន

### ១) *<u>សចសពុំចាំបាច់សម្រេចសេចក្តីលើបញ្ហាការឃុំខ្លួនទេ</u>*

53. ជាគោលការណ៍ និងស្របតាមវិធាន២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៦៣-៦ នៃវិធានផ្ទៃក្នុង ក្នុងករណីដែលមានការចោទប្រកាន់ពីឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបង្គាប់សម្រាប់រយៈពេលមួយឆ្នាំជាអតិបរមា។ ដូច្នេះ នៅពេលផុតថិរវេលានេះ ជាគោលការណ៍ ត្រូវមានការដោះលែងឲ្យមានសេរីភាព។

54. ក៏ប៉ុន្តែ អត្ថបទច្បាប់បានចែងអំពីលទ្ធភាពដែលផ្តល់ដល់សចស ក្នុងការបង្គាប់ឲ្យបន្តការឃុំខ្លួនសម្រាប់រយៈពេលមួយឆ្នាំទៀត។ វាជាអញ្ញត្រកម្មនៃគោលការណ៍ដោះលែងឲ្យមានសេរីភាព។ ចេញពីន័យច្បាប់នេះ និងក្នុងករណីដែលសចសយល់ឃើញថា វាជាការចាំបាច់ដោយឡែកមួយក្នុងការបន្តមួយឆ្នាំទៀតនេះ ការបន្តនេះអាចធ្វើត្រឹមតែមួយឆ្នាំជាបន្ថែមប៉ុណ្ណោះ។ ជាងនេះទៅទៀត

---

[45] TPIY- *រដ្ឋអាជ្ញា c. Blagojevic*, IT-02-60, សេចក្តីសម្រេចទាក់ទងនឹងសំណើដែលស្នើឡើងដោយ Blagojevic ដោយអនុវត្តន៍តាមមាត្រា 15 B) នៃវិធាន ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ១៥ ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត

លើសពីការបន្តពីរលើកនេះ ការឃុំខ្លួននឹងត្រូវបានចាត់ទុកថា ខុសច្បាប់ ទោះជាវិធាន៦៣-៣ បានកំណត់លក្ខខណ្ឌយ៉ាងណាក៏ដោយ។

55. វិធានទាំងនេះមានកម្មវត្ថុ បង្ហាញយ៉ាងជាក់លាក់នូវសញ្ញាណនៃពេលវេលាក្នុងសេចក្តីសម្រេចឃុំខ្លួន និងរំលឹកឡើងវិញថា ទោះជាមានយុត្តិកម្មលើការឃុំខ្លួនក៏ដោយ សច្ចធារណ៍គឺជាសច្ចធារណ៍នៃសេរីភាពក្នុងអម្លុងពេលស៊ើបអង្កេត ហើយបើទោះជាបទឧក្រិដ្ឋដែលកំពុងស៊ើបអង្កេតនោះមានលក្ខណៈធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ វិធានទាំងនេះបំពេញលើបន្ថែមលើវិធាន ៦៤-១នៃវិធានផ្ទៃក្នុង ដែលបានដាក់បន្ទុកដល់សចស "នៅពេលណាក៏បាននៅក្នុងអម្លុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ន តាមគំនិតផ្តួចផ្តើមរបស់ខ្លួន(...)ត្រូវចេញដីកាបង្គាប់ឲ្យដោះលែងជនត្រូវចោទ ប្រសិនបើលក្ខខណ្ឌតម្រូវនៃការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងក្នុងវិធាន៦៣ ខាងលើ លែងមានទៀតហើយ" [46]។ វិធាន<u>ទាំងពីរ</u>នេះ មានប្រយោជន៍រៀងខ្លួន និងមិនអាចច្រឡំគ្នាបានទេ។

56. ផ្ទុយពីអ្វីដែលខ្លួនបានយល់ឃើញក្នុងសេចក្តីសម្រេចរបស់ខ្លួន សចស "ពុំចាំបាច់ពិនិត្យពីលក្ខខណ្ឌនៃការឃុំខ្លួនឡើងវិញ និងសម្រេចពីការបន្តថេរវេលានៃការឃុំខ្លួន ដោយមិនអាចរង់ចាំបាន"[47] នៅពេលដីកាសម្រេចឃុំខ្លួនផុតរយៈពេលកំណត់។ <u>ជាងនេះទៀត យោងតាមមាត្រា ៣៨នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ ព្រោះគាត់ត្រូវបានសន្មតថាគ្មានទោស។</u>

57. ដូច្នេះ សចសបានធ្វើឲ្យបញ្ច្រាស់ឡើងវិញនូវសច្ចធារណ៍ទាំងអស់ដែលគួរតែត្រូវបានលើកឡើងនៅពេលផុតរយៈពេលមួយឆ្នាំនៃការឃុំខ្លួន ដែលថាការឃុំខ្លួន គឺជាគោលការណ៍ ដែលការពិត វាគ្រាន់តែជាអញ្ញត្រកម្មប៉ុណ្ណោះ។ ការណ៍នេះបង្ហាញពីកង្វះភាពអព្យាក្រិតរបស់សចសក្នុងផ្នែកនេះ ទោះជាខ្លួនបានបដិសេធក៏ដោយ។[48]

## ២) ***<u>សេចក្តីសម្រេចបន្តឃុំខ្លួនមិនចាំបាច់ ហើយក៏មិនមានយុត្តិកម្មដែរ</u>***

58. ដើម្បីធ្វើយុត្តិកម្មលើសេចក្តីសម្រេចបន្តឃុំខ្លួនរបស់ខ្លួន សចសផ្អែកលើអំណះអំណាងនៅក្នុងដីកាសម្រេចបដិសេធដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ តុលា ២០០៨។ ដោយយល់ឃើញថា

[46] វិធាន ៦៤-១នៃវិធានផ្ទៃក្នុង មាត្រា ២១៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[47] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ១៦

[48] ផ្ទុយពីអ្វីដែលសចសលើកឡើង ក្រុមការពារក្តីមិនបានស្នើសុំបដិសេធទទួលស្គាល់សមត្ថកិច្ចរបស់សចសទេ ក្រុមការពារក្តីបានរិះគន់អំពីជំហររបស់សចសក្នុងការងារស៊ើបអង្កេត ដែលបានតម្រូវឲ្យសចសមានការប្រុងប្រយ័ត្នក្នុងកម្រិតខ្ពស់ (សូមមើលត្រង់សំណុចនេះ ក្នុងការជំទាស់របស់ក្រុមការពារក្តី កថាខណ្ឌ២៩ ដល់៣២)។ បន្ទាប់មក ក្រុមការពារក្តីបានយល់ឃើញថា "ក្នុងករណីនេះ សចសពុំអាចរក្សាបាននូវគម្លាតដែលច្បាប់បានកំណត់ឲ្យខ្លួននោះឡើយ" (កថាខណ្ឌ៣៣)។

សចសបានសម្រេចលើ "លក្ខខណ្ឌកំណត់ដោយវិធាន ៦៣(៣)នៃវិធានផ្ទៃក្នុង ដោយគិតពីពេលវេលាកន្លងផុតទៅ ចាប់តាំងពីការឃុំខ្លួនបណ្ដោះអាសន្ន(...) [ហើយថា] ចាប់តាំងពីពេលនោះមក មិនមានស្ថានភាពណាមួយមានការផ្លាស់ប្ដូរ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ជំហរដែលសចសបានប្រកាន់យកនៅពេលនោះទេ"[49]សចសសរុបថា "ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាការចាំបាច់ និងត្រូវតែធ្វើជាបន្តទៅទៀត"[50]។

59. ជាដំបូង សហមេធាវីយល់ថា ការផុតកំណត់នៃកាលកំណត់តាមច្បាប់នៃការឃុំខ្លួន គឺជាការផ្លាស់ប្ដូរមួយ និងជាកាលៈទេសៈមួយដែលត្រូវយកមកពិចារណា[51]។ កាលៈទេសៈនេះបានដាក់កំហិតយ៉ាងតឹងរ៉ឹងដល់សចសក្នុងការត្រួតពិនិត្យលើលក្ខខណ្ឌទាំងឡាយ និងសូមឱ្យសចសពិនិត្យមើលថា តើមាន "តម្រូវការជាចាំបាច់ពិតប្រាកដនៃផលប្រយោជន៍សាធារណៈ ធ្វើយុត្តិកម្មលើអញ្ញត្រកម្មលើវិធាននៃសេរីភាពជាបុគ្គលឬទេ។"[52]

60. ប៉ុន្តែ សហមេធាវីសូមគូសបញ្ជាក់ថា សេចក្ដីសម្រេច ចុះថ្ងៃទី២៨ តុលា ២០០៨ មិនបានបង្ហាញថា ការឃុំខ្លួនជាការចាំបាច់ទេ[53]។ លើសពីលក្ខណៈដោយបំពាននៃការឃុំខ្លួន និងអនិយ័តភាពផ្សេងៗនៃនីតិវិធីដែលបានជំទាស់ដោយក្រុមការពារក្ដីក្នុងសុំណើសុំរបស់ខ្លួននោះ (ហើយដែលត្រូវបានសចសធ្វើមិនដឹងមិនលឺយ៉ាងសាមញ្ញ[54]) សហមេធាវីការពារក្ដីបានបង្ហាញយ៉ាងច្បាស់ថា ការដោះលែងលោក ខៀវ សំផន ឱ្យមានសេរីភាព មិនបង្កឱ្យមានហានិភ័យនៃការកៀបសង្កត់លើ

---

[49] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ២៦

[50] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ២៩

[51] ដោយឡែក តាមច្បាប់បារាំង វាជាតម្រូវការតាមច្បាប់មួយ៖ "ខាងផ្នែកព្រហ្មទណ្ឌ ដោយហេតុថា ថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើសពីរយៈពេលមួយឆ្នាំ(...) សេចក្ដីសម្រេចដែលបង្គាប់ឱ្យបន្តឃុំខ្លួន ឬទាត់ចោលសំណើសុំឱ្យដោះលែងត្រូវមានបញ្ជាក់ការចង្អុលបង្ហាញដោយឡែក ដែលក្នុងករណីនេះធ្វើយុត្តិកម្មលើការបន្តនៃពត៌មាន និងថេរវេលាដែលអាចប្រមើលទុកជាមុនបានក្នុងការទៅដល់សម្រេចនីតិវិធី" (មាត្រា១៤៥-៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង) សូមមើលការអនុវត្តតាមអត្ថបទនេះ តុលាការកំពូលផ្នែកព្រហ្មទណ្ឌ សវនាការសាធារណៈថ្ងៃទី១០ ឧសភា ២០០១ ព្រឹត្តិបត្រព្រហ្មទណ្ឌ២០០១ លេខ១១៧ ទំព័រ៣៥៤

[52] តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស Neumeister តទល់នឹងប្រទេសអូទ្រីស ថ្ងៃទី២៧ មិថុនា ១៩៦៨ សំណើសុំលេខ 1936/63 កថាខណ្ឌ៥

[53] សូមមើលត្រង់ចំណុចនេះ សំណើសុំជាបន្ទាន់ឱ្យដោះលែងឱ្យមានសេរីភាព ថ្ងៃទី៨ តុលា ២០០៨ *ឯកសារតុលាការ C40* និងសារណាបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដីប្រឆាំងនឹងដីកាសម្រេចបដិសេធដោះលែងឱ្យមានសេរីភាពថ្ងៃទី២៨ តុលា ២០០៨ ចុះថ្ងៃទី២៧ វិច្ឆិកា ២០០៨ ថ្ងៃទី២៧ វិច្ឆិកា ២០០៨ *ឯកសារតុលាការ C40/5/1*។

[54] សំណើសុំជាបន្ទាន់ឱ្យដោះលែងឱ្យមានសេរីភាព កថាខណ្ឌ៣៦ និង៣៧

សាក្សី ឬជនរងគ្រោះ[55] មិនអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ[56] និងមិនបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ឡើយ[57]។ ដូច្នេះ សចសអាចយល់ឃើញយ៉ាងពិតប្រាកដថា វិធានការណ៍ជាជម្រើសមួយផ្សេងពីការឃុំខ្លួនមានលក្ខណៈត្រឹមត្រូវ។ សចសបានបដិសេធពិចារណាពីជម្រើសនេះ ហើយក៏មិនបានផ្តល់មូលហេតុនៃការបដិសេធរបស់ខ្លួននេះដែរ។[58]

61. ផ្ទុយមកវិញ យើងឃើញច្បាស់ហើយថា ការឃុំខ្លួនលោក ខៀវ សំផន បានមកដល់កាលកំណត់ទីមួយតាមច្បាប់ហើយ បើទោះជាក្រុមការពារក្តីបានលើកឡើងអំពីអនិយ័តភាពហើយក៏ដោយ។ ក្រុមការពារក្តីសូមរំលឹកឡើងវិញថា លោកខៀវ សំផន ចាស់ហើយ ហើយសុខភាពរបស់គាត់ក៏មានភាពទន់ខ្សោយផងដែរ[59]។

62. ក្នុងបរិបទនេះ ការបន្តការឃុំខ្លួនគឺជាវិធានការណ៍មួយស្វ័យប្រវត្តិ (សូមមើល ជារួម[60]) ដែលមូលហេតុជាក់ស្តែង គឺភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានចោទប្រកាន់ទៅលើជនត្រូវចោទ[61]។ ដូច្នេះ វាគឺជាសេចក្តីសម្រេចមួយដែលមានភាពលម្អៀងរបស់ចៅក្រមដែលលែងមានសមត្ថកិច្ចសម្រេចសេចក្តីទៀតហើយ។

### គ- លោក ខៀវ សំផន ត្រូវបានឃុំខ្លួនដោយពុំមានដីកាសម្រេច ហើយគាត់ត្រូវតែបានដោះលែង

#### 1) *សេចក្តីសម្រេចបន្តឃុំខ្លួនធ្វើអោយនីតិវិធីខុសប្រក្រតីមួយ និងសេចក្តីសម្រេចតាមអំពើចិត្តមានមានសុពលភាព*

63. ក្នុងករណីនេះ សហចយល់ឃើញថា វាពុំមែនជាសមត្ថកិច្ចរបស់ខ្លួន "ក្នុងការសម្រេចពីចំណុចដែលចង់ដឹងថា តើអាចមានប្រយោជន៍ ឬមិនមានប្រយោជន៍នោះទេ"[62]។

---

[55] ដូចគ្នា កថាខណ្ឌ៤០ ៤១ ដូចគ្នា ពីកថាខណ្ឌ៤៦ ដល់៥៩

[56] ដូចគ្នា ពីកថាខណ្ឌ៤៣ ដល់៤៧ ដូចគ្នា ពីកថាខណ្ឌ៦០ ដល់៧៤

[57] ដូចគ្នា កថាខណ្ឌ៤៨ ៤៩ ដូចគ្នា ពីកថាខណ្ឌ៧៥ ដល់៨២

[58] ដូចគ្នា កថាខណ្ឌ៣៣ ៣៤ ដូចគ្នា ពីកថាខណ្ឌ៣៧ ដល់៤២

[59] ដូចគ្នា កថាខណ្ឌ៤២ ដូចគ្នា ពីកថាខណ្ឌ៨៣ ដល់៨៨

[60] ការឃុំខ្លួនជាបណ្តោះអាសន្នជនត្រូវចោទ៤នាក់ទៀតត្រូវបានធ្វើឡើង - ដីកាសម្រេចបន្តថេរវេលាឃុំខ្លួនជាបណ្តោះអាសន្ន ថ្ងៃទី១៦ កញ្ញា ២០០៨ សម្រាប់លោក នួន ជា *ឯកសារតុលាការ C9/3* ថ្ងៃទី១១ វិច្ឆិកា ២០០៨ សម្រាប់លោក អៀង សារី *ឯកសារតុលាការ C22/4* និងសម្រាប់ អ្នកស្រី អៀង ធិរិទ្ធ *ឯកសារតុលាការ C20/4*

[61] អំណះអំណាងនេះត្រូវបានលើកយកមកបកស្រាយយ៉ាងវែងដោយក្រុមការពារក្តី នៅក្នុងសារណាបណ្តឹងរបស់ខ្លួនប្រឆាំងនឹងដីកាសម្រេចបដិសេធការដោះលែង ថ្ងៃទី២៨តុលា ២០០៨ ចុះថ្ងៃទី២៧ វិច្ឆិកា ២០០៨ កថាខណ្ឌ២៤ ដល់៤២។

[62] ដីកាសម្រេចបន្តឃុំខ្លួន កថាខណ្ឌ ១៣

64. ដើម្បីអោយត្រឹមត្រូវតាមច្បាប់ ដីកាសម្រេចបន្តឃុំខ្លួនត្រូវតែ "មានបញ្ជាក់មូលហេតុ"[63] "ជាលាយល័ក្ខអក្សរ"[64] និង"លម្អិត"[65]។ យោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប ដើម្បីបំពេញតាមកាតព្វកិច្ចបញ្ជាក់មូលហេតុ មិនត្រឹមតែបញ្ជាក់មូលហេតុនៃសេចក្តីសម្រេចរបស់ខ្លួនយ៉ាងលម្អិតតែប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមនៃការឃុំខ្លួននេះត្រូវតែមានអំណះអំណាងថា មូលហេតុសំខាន់ពីលើកដំបូងក្នុងការសម្រេចឃុំខ្លួន ពុំបានបាត់បង់តំលៃរបស់វាទៅតាមពេលវេលា[66] សេចក្តីសម្រេចនេះផ្អែកលើ ទាំងភាពស្របច្បាប់នៃការឃុំខ្លួនលើកដំបូង ទាំងលើភាពស្របច្បាប់នៃថេរវេលាថ្មីដែលបានសម្រេចនេះ។ ដូច្នេះ ក្នុងន័យនេះ ជាវិបាក ការសម្រេចឃុំខ្លួននេះធ្វើអោយរយៈពេលដំបូងនេះទៅជាស្របច្បាប់ ព្រមទាំងឲ្យអានុភាពរបស់វាអាចបន្តទៅទៀត។

65. ដូច្នេះ និងក្នុងករណីដែលសហចមានបំណងយ៉ាងជាក់ស្តែងថា មិនសម្រេចសេចក្តីលើនីត្យានុកូលភាពនៃការឃុំខ្លួនលើកដំបូង វាប្រាកដជាអាចទៅរួចក្នុងការបង្អង់រឿងក្តីសិន និងបង្គាប់អោយដោះលែងលោក ខៀវ សំផន អោយមានសេរីភាពដូចដែលក្រុមការពារក្តីបានស្នើសុំ[67]។ ផ្ទុយមកវិញ ពេលសម្រេចលើការបន្តការឃុំខ្លួន សចសមានកាតព្វកិច្ចក្នុងការសម្រេចលើនីត្យានុកូលភាពនៃការឃុំខ្លួនលើកដំបូង។

66. ហើយតាមអង្គហេតុ សចសពុំបានលះបង់កាតព្វកិច្ចនោះឡើយ។ ទោះជាគោលជំហរជាគោលការណ៍របស់ពួកគេយ៉ាងណាក៏ដោយ គំនិតរបស់សចសបានបង្ហាញយ៉ាងច្បាស់លើចំណុចនេះ (ម្តងទៀត)៖ «ដោយបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ សហមេធាវីការពារក្តីបានលះបង់ចោលដោយស្ម័គ្រចិត្តនូវសិទ្ធិតវ៉ាចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ពោលគឺអង្គបុរេជំនុំជម្រះ អំពីលក្ខខណ្ឌទាំងឡាយនៃការប្រព្រឹត្តទៅនៃនីតិវិធី។»[68]

---

[63] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៦៣ (៧)នៃវិធានផ្ទៃក្នុង

[64] វិធាន ៦៣ (៧)នៃវិធានផ្ទៃក្នុង

[65] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[66] សូមមើលករណី : តុលាការព្រហ្មទណ្ឌអឺរ៉ុប *Letellier តទល់នឹង បារាំង*, ថ្ងៃទី២៦ មិថុនា ១៩៩១ សំណើសុំលេខ 12369/86, កថាខណ្ឌ ៥៥ និង៥៦ ; តុលាការព្រហ្មទណ្ឌអឺរ៉ុប *Tomasiតទល់នឹង បារាំង*, ថ្ងៃទី២៧ សីហា ១៩៩២, សំណើសុំលេខ 12850/87, កថាខណ្ឌ 84 ; តុលាការព្រហ្មទណ្ឌអឺរ៉ុប *Zannouti តទល់នឹង បារាំង*, ថ្ងៃទី៣១ កក្កដា ២០០១ សំណើសុំលេខ 42211/98, កថាខណ្ឌ 43 ; តុលាការព្រហ្មទណ្ឌអឺរ៉ុប *Muller តទល់នឹង បារាំង*, ថ្ងៃទី១៧ មិនា ១៩៩៧17 mars 1997, សំណើសុំលេខ 21802/93, para. 35 ; តុលាការព្រហ្មទណ្ឌអឺរ៉ុប *Debboubតទល់នឹង បារាំង*, ថ្ងៃទី៩ វិច្ឆិកា ១៩៩៩ សំណើសុំលេខ. 37786/97 កថាខណ្ឌ៣៩ ជាដើម។

[67] ការកត់សម្គាល់របស់ក្រុមការពារក្តី កថាខណ្ឌ៣៦ ដល់៤១។

[68] ដីកាសម្រេចបន្តការឃុំខ្លួន កថាខណ្ឌ១៣

67. ក្រុមការពារក្តីសូមសួរថាៈ ប្រសិនបើសចសពុំមានសមត្ថកិច្ចក្នុងការសម្រេចលើនិយ័តភាពនៃនីតិវិធី ហេតុអ្វីមានការអធិប្បាយនេះ ? ជាបញ្ច្រាស់មកវិញ ប្រសិនបើខ្លួនមានសមត្ថកិច្ច តើខ្លួនអាចអះអាងយ៉ាងស្របច្បាប់ថា ជនត្រូវចោទបានលះបង់ចោលដោយស្ម័គ្រចិត្តនូវសិទ្ធិតវ៉ា (...) អំពីលក្ខខណ្ឌទាំងឡាយនៃការប្រព្រឹត្តទៅនៃនីតិវិធីទេ?

68. យោងតាមមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "នៅរាល់ពេលដែលបានទទួលបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនីយ័តភាពនៃនីតិវិធីនិងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីនេះ។ កាលណាពិនិត្យឃើញថា មូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងក្នុងមាត្រា២៨០ (អានុភាពនៃមោឃកម្ម) នៃក្រមនេះ។"។

69. ក្នុងសវនាការប្រឆាំងនឹងការឃុំខ្លួន កាលពីថ្ងៃទី២៣ មេសា ២00៨ សហមេធាវីអន្តរជាតិបានថ្លែងថា "សំណុំរឿងមានឯកសារចំនួន១៥ 000 ទំព័រ ពុំមានការបកប្រែជាភាសាបារាំង ដែលភាសានេះក៏ជាភាសាផ្លូវការមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់អវតក។ ដោយសារគាត់ជាមេធាវីបារាំងគាត់បានប្រកាសថា មានការប៉ះពាល់ដល់សិទ្ធិមេធាវីការពារក្តី (គាត់)(....)មិនមានលទ្ធភាព(....) (ហើយ) នេះជាមូលហេតុនៃមោឃភាពនីតិវិធី។"[69]។

70. ជាដំបូង លោកមេធាវី Vergès ត្រូវបានដាក់ទោស ហើយសវនាការក៏ត្រូវបានលើកពេល។ បន្ទាប់មក តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី២ តុលា ២00៨ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "វិធាន ៧៥(៤) រារាំងមេធាវីចំពោះការលើកឡើងអង្គហេតុ និងអង្គច្បាប់បន្ថែម នៅក្នុងដំណាក់កាលនេះ ដែលអង្គហេតុ និងអង្គច្បាប់ទាំងនេះមិនបានលើកឡើងក្នុងសារណាបណ្តឹងឧទ្ធរណ៍"[70]។ វិធាន ៧៥(៤) ចែងថា "ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកក្នុងពេលសវនាការ បញ្ហាអង្គហេតុ ឬអង្គច្បាប់ដែលមិនមានចែងក្នុងសារណាបណ្តឹងឧទ្ធរណ៍ឡើយ"។

71. ក៏ប៉ុន្តែ ក្រុមការពារក្តីមិនបានលើកពីចំណុចអង្គហេតុ ឬអង្គច្បាប់ថ្មីជាមូលដ្ឋានដែលខ្លួនជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឡើយ តែខ្លួនបានទាញចំណាប់អារម្មណ៍របស់អង្គបុរេជំនុំជម្រះលើអត្ថិភាពនៃមូលហេតុមោឃភាពដែលបង្កឱ្យមានកំហុសដល់នីតិវិធីទាំងមូល។អង្គបុរេជំនុំជម្រះ

---

[69] កំណត់ហេតុសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២00៨ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២00៨ *ឯកសារតុលាការ C26/I/26 ទំព័រ ៤/៧*

[70] សេចក្តីបង្គាប់ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១២ ខែតុលា ឆ្នាំ២00៨ *ឯកសារតុលាការ C26/I/29 កថាខណ្ឌទី៧ ដល់ទី៩*

បានបដិសេធលើកឡើងអំពីបញ្ហានេះដោយខ្លួនឯងផ្ទាល់។ ឥឡូវនេះ អង្គបុរេជំនុំជម្រះត្រូវដោះស្រាយលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការបកប្រែរបស់សចស។

72. ជាគោលការណ៍ មាត្រា ៤១៧ នៃក្រមនីតិវិធីចែងថា "សាលដីកានៃសភាស៊ើបសួរ (...) អាចត្រូវប្តឹងសាទុក្ខបាន" នេះមិនមែនជាការអនុវត្តជាក់ស្តែងនៅអ.វ.ត.កទេ។ ដូច្នេះ ការដកបណ្តឹងឧទ្ធរណ៍កាលពីថ្ងៃទី៨ តុលា ២០០៨ គឺជាមធ្យោបាយតែមួយគត់សម្រាប់ក្រុមការពារក្តី ដើម្បីជំទាស់នឹងភាពបន្ទាន់បង្ខំ និងការប៉ះពាល់ដល់នីត្យានុកូលភាពនៃនីតិវិធី និងដើម្បីលើកបញ្ហានេះចំពោះអាជ្ញាធរថ្មីមួយ។

73. ដូច្នេះ ទោះក្នុងករណីណាក៏ដោយ សចសមានកាតព្វកិច្ចត្រូវពិចារណាថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើការឃុំខ្លួន បានធ្វើឡើងយ៉ាងយឺតយ៉ាវបំផុត ហើយថា ត្រូវមានការដោះលែងឲ្យមានសេរីភាព៖ ស្របតាមមាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន សាលដីការបស់សភាស៊ើបសួរត្រូវសម្រេចចេញនៅក្នុងរយៈពេលដប់ប្រាំថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឲ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះបង្កជាឧបសគ្គមិនឲ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ។"

74. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបញ្ហាឃុំខ្លួននេះ បានធ្វើឡើងនៅថ្ងៃទី២ តុលា ២០០៨ ពោលគឺក្នុងរយៈពេល១០ខែក្រោយពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ[71]។ ភាពយឺតយ៉ាវនេះរំលោភលើថិរវេលាដែលបានកំណត់ដោយច្បាប់កម្ពុជា ហើយវាផ្ទុយទៅនឹង "តម្រូវការចាំបាច់នៃភាពឆាប់រហ័ស" ដែលបានកំណត់ដោយច្បាប់អន្តរជាតិ[72]។ តាមការយល់ដឹងរបស់ក្រុមការពារក្តី ពុំមានអំណះអំណាងណាមួយត្រូវបានលើកមកដើម្បីធ្វើយុត្តិកម្មលើរយៈពេលកំណត់នេះឡើយ។[73]

---

[71] សេចក្តីបង្គាប់ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/29*

[72] សូមមើលចំណុចនេះ ការកត់សម្គាល់លើការបន្តឃុំខ្លួន កថាខណ្ឌ២២ និង២៣

[73] ការណ៍ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា "មកទល់ពេលនេះ ការលើកពេលសវនាការនេះមានរយៈពេលជិតបួន (៤) ខែហើយ។ អង្គបុរេជំនុំជម្រះមិនទាន់ទទួលបានការជូនដំណឹងណាមួយ (អំពីជនត្រូវចោទ និងមេធាវីរបស់គាត់) អំពីការត្រៀមខ្លួនរួចរាល់ក្នុងការបន្តសវនាការ ឬក៏អំពីបំណងរបស់ខ្លួនចង់ឲ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេច ដោយមិនចាំបាច់បើកសវនាការជេញដោល ឬក៏ផ្តល់ព័ត៌មានផ្សេងៗទៀតចំពោះបណ្តឹងឧទ្ធរណ៍នេះឡើយ" (សេចក្តីបង្គាប់ដល់មេធាវីការពារក្តីស្តីពី

75. ក្នុងករណីនេះ នីតិវិធីទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នគឺទុកជាមោឃៈ[74]។ ដូច្នេះ ដីកាសម្រេចបន្តថេរវេលាឃុំខ្លួនត្រូវចាត់ទុកថា គ្មានអត្ថិភាព។ ហើយដូច្នេះ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនដោយគ្មានដីកាសម្រេចឃុំខ្លួន។

*២) លោក ខៀវ សំផន ត្រូវតែបានដោះលែងជាបន្ទាន់ ហើយគាត់មានសិទ្ធិទទួលបានការជួសជុលព្យសនកម្ម*

76. តាមច្បាប់ ត្រូវចាត់ថាគ្មានអត្ថិភាពនៅពេលដែលកិច្ចនោះមានលក្ខណៈខុសច្បាប់ ហើយវាប៉ះពាល់ដល់សេរីភាពរបស់បុគ្គលដោយផ្ទាល់[75]។ ក្នុងនីតិវិធីព្រហ្មទណ្ឌបារាំង វាគឺជា "បច្ចេកទេសដោយឡែកសម្រាប់ជួយសង្គ្រោះ"[76] ដែលអនុញ្ញាតឱ្យមានការគោរពគំនាបដែលបានដាក់កំហិតដោយគោលការណ៍នៃនីត្យានុកូលភាព។

77. នៅពេលដែលឃើញថា ជនត្រូវចោទម្នាក់ត្រូវបានឃុំខ្លួន ដោយសារដីកាមួយដែលមោឃៈ ឬពុំមានអត្ថិភាព តុលាការកំពូលផ្នែកព្រហ្មទណ្ឌយល់ថា ជនត្រូវចោទម្នាក់ត្រូវបានឃុំខ្លួន ដោយគ្មានដីកាសម្រេច[77] ហើយសម្រេចថា អង្គចៅក្រមប្រកាន់[78] "ត្រូវតែ"សម្រេចឱ្យមានការដោះលែងឱ្យមានសេរីភាព តាមការផ្តើមគំនិតរបស់ខ្លួន[79]។

78. យោងតាមក្រុមការងាររបស់អង្គការសហប្រជាជាតិ អំពីការឃុំខ្លួនដោយបំពាន "ការមិនកត់សម្គាល់ទាំងស្រុង ឬក៏មួយផ្នែក នៃបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ ដូចដែលបានចែងក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងក្នុងបទដ្ឋានអន្តរជាតិសំខាន់ៗដែលបានព្រមព្រៀងដោយប្រទេសដែលពាក់ព័ន្ធ គឺជាភាពធ្ងន់ធ្ងរមួយ

---

បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី២ តុលា ២០០៨ *ឯកសារតុលាការ C26/I/27 កថាខណ្ឌ៦)* អាចយកមកពិចារណាយ៉ាងត្រឹមត្រូវថា ជាកាលៈទេសៈដែលមិនអាចប្រមើលមើលទុកជាមុន ឬមិនអាចគេចផុតបាន ដែលជាឧបសគ្គដល់ការចេញសាលដីកាតាមពេលកំណត់បានឡើយ ។

[74] CHAMBON (P.), GUERY (C.), *Droit et pratique de l'instruction préparatoire*, Dalloz Action 2007/2008, កថាខណ្ឌ 241.69

[75] តុលាការកំពូល ផ្នែកព្រហ្មទណ្ឌ ថ្ងៃទី៤ មករា ១៩៨៣ ព្រឹត្តិបត្តិព្រហ្មទណ្ឌ លេខ៣

[76] ADIDA-CANAC (H.), « Actualité de l'inexistence des actes juridiques », Publications de la Cour de cassation, របាយការណ៍ប្រចាំឆ្នាំ ២០០៤ កថាខណ្ឌ ៥០

[77] តុលាការកំពូល ផ្នែកព្រហ្មទណ្ឌ ថ្ងៃទី១៣ តុលា២០០៤ ព្រឹត្តិបត្តិព្រហ្មទណ្ឌ លេខ២៤២

[78] តាមច្បាប់បារាំង អង្គចៅក្រមប្រកាន់ ដូចគ្នានឹងអង្គបុរេជំនុំជម្រះ

[79] CHAMBON (P.), GUERY (C.), *Droit et pratique de l'instruction préparatoire*, Dalloz Action 2007/2008, កថាខណ្ឌ 241.69

ដូចជាការបាត់បង់នូវសេរីភាពដែលមានលក្ខណៈដោយបំពាន"[80]។ ដោយឡែក មាត្រា ៩-៥ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ បានចែងថា "ជនណាដែលបានរងគ្រោះ ដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង"។

79. ក្នុងករណីនេះ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនអស់ជាច្រើនខែ ដោយគ្មានដីកាសម្រេច ហើយ សម្រាប់ការឃុំខ្លួនមួយដែលគាត់យល់ថា ជាការធ្វើឡើងដោយបំពាន។ ដូច្នេះ គាត់មានសិទ្ធិ ទទួលបានការជួសជុលព្យសនកម្ម។

## IV. ហេតុដូចនេះ

80. សហមេធាវីការពារក្តី សូមស្នើអោយអង្គបុរេជំនុំជម្រះមេត្តា៖

- **យល់ឃើញថា** លោក ខៀវ សំផន ត្រូវបានឃុំខ្លួន ដោយសារដីកាសម្រេចមួយដែល មោឃៈ
- **បង្គាប់អោយ**មានការដោះលែងលោក ខៀវ សំផន **ជាបន្ទាន់**
- និងអនុញ្ញាតឲ្យមាន**ការជួសជុលព្យសនកម្ម**ដល់លោក ខៀវ សំផន ដោយសារមូលហេតុ ការឃុំខ្លួនដោយបំពាន និងគ្មានដីកាសម្រេច

**ក្រោមការរក្សាបទនីយគ្រប់យ៉ាង**

លោកមេធាវី ស សូវាន | លោកមេធាវី Jacques VERGES

[80] ក្រុមការងាររបស់អ.ប.ជ (ONU) នីតិកាលទី៥៨នៃសិទ្ធិមនុស្សនៅ អ.ប.ជ "Abassi Madani និង Ali Benhadj ការឃុំខ្លួន ដោយបំពាន ? "